# III - ទីស្តីការគណៈរដ្ឋមន្ត្រី

## ១ - អនុក្រឹត្យ

រាជធានីភ្នំពេញ, ថ្ងៃទី ២៤ ខែ សីហា ឆ្នាំ ១៩៩៥

**អនុក្រឹត្យលេខ ៦៦ អនក្រ.បក**

**ស្តីពីការបង្កើតគណៈកម្មាធិការជាតិរៀបចំ**

**ខ្សែក្រវាត់ បៃតងជុំវិញ រាជធានីភ្នំពេញ**

***

**រាជរដ្ឋាភិបាលកម្ពុជា**

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ សន/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- យោងតាមលទ្ធផល នៃ សម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី នាថ្ងៃទី ០៤ ខែ វិច្ឆិកា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំខ្សែក្រវាត់ បៃតងជុំវិញរាជធានីភ្នំពេញ
- យោងតាមលទ្ធផល នៃកិច្ចប្រជុំអន្តរក្រសួង នាថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ១៩៩៥ ស្តីពីការពិភាក្សាដោះស្រាយបញ្ហាសំណង់អនាធិបតេយ្យ និងការរៀបចំខ្សែក្រវាត់ បៃតង ជុំវិញរាជធានីភ្នំពេញ .

**សំរេច**

**មាត្រា ១ :** ត្រូវបានបង្កើតគណៈកម្មាធិការជាតិរៀបចំខ្សែក្រវាត់ បៃតង នៅជុំវិញរាជធានីភ្នំពេញ ដែលមានសមាសភាព ដូចខាងក្រោម ÷

១-ឯកឧត្តម **អ៊ឹង គៀត** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសាធារណការ និង ដឹកជញ្ជូន ប្រធាន

២-ឯកឧត្តម **ជិន គីមស្រេង** អនុរដ្ឋលេខាធិការ ក្រសួងសាធារណការ និង ដឹកជញ្ជូន អនុប្រធាន

៣-តំណាង ក្រសួងការពារជាតិ (ថ្នាក់អនុរដ្ឋលេខាធិការឡើង) សមាជិក

៤-តំណាង ក្រសួងមហាផ្ទៃ (ថ្នាក់អនុរដ្ឋលេខាធិការឡើង) សមាជិក

៥-តំណាង ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ (ថ្នាក់អនុរដ្ឋលេខាធិការឡើង ) សមាជិក

៦-តំណាង ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល (ថ្នាក់អនុរដ្ឋលេខាធិការឡើង) សមាជិក

៧-តំណាង ក្រសួងអភិវឌ្ឍន៍ជនបទ (ថ្នាក់អនុរដ្ឋលេខាធិការឡើង) សមាជិក

៨-តំណាង សាលាក្រុងភ្នំពេញ (ថ្នាក់អភិបាលរងឡើង) សមាជិក

៩-តំណាង អភិបាលខេត្តកណ្តាល (ថ្នាក់អភិបាលរងឡើង) សមាជិក

១០-តំណាង អភិបាលខេត្តកំពង់ស្ពឺ (ថ្នាក់អភិបាលរងឡើង) សមាជិក

១១-តំណាង ទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក

១២-លោក **ហែម យឹមអេង** ប្រធាននាយកដ្ឋាន នគរោបនីយកម្ម-លំនៅដ្ឋាន ក្រសួងសាធារណការ និងដឹកជញ្ជូន សមាជិករាយការណ៍

**មាត្រា ២** : គណៈកម្មាធិការជាតិរៀបចំខ្សែក្រវាត់ បៃតង ជុំវិញរាជធានីភ្នំពេញ មានភារកិច្ច ÷

- សិក្សាស្រាវជ្រាវ រៀបចំធ្វើផែនទីកំណត់តំបន់ដែលត្រូវរៀបចំខ្សែក្រវាត់ បៃតង ជុំវិញរាជធានីភ្នំពេញ
- កសាងផែនការនិងអនុវត្តគំរោងការក្នុងការរៀបចំតំបន់បៃតងនេះ អោយទៅជាតំបន់អភិវឌ្ឍន៍ដំណាំផ្លែឈើ បន្លែ មានបណ្តាញគមនាគមន៍ និងទឹក សំរាប់ផ្គត់ផ្គង់អោយរាជធានីភ្នំពេញ
- ទំនាក់ទំនងជាមួយអន្តរជាតិ ដើម្បីសុំជំនួយសំរាប់អនុវត្តផែនការ និងគំរោងការ នៃការរៀបចំតំបន់ បៃតងនេះ
- ទំនាក់ទំនង និងសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីពិភាក្សាដោះស្រាយរាល់បញ្ហាដែលមានការពាក់ព័ន្ធទៅនឹងការរៀបចំ និងកិច្ចដំណើរការនៃការកសាងខ្សែក្រវាត់បៃតង ជុំវិញរាជធានីភ្នំពេញ ។

- បូកសរុប រាយការណ៍អំពីលទ្ធផល នៃការងារនេះជូនគណៈរដ្ឋមន្ត្រី តាមដំណាក់កាលនីមួយ ។

**មាត្រា ៣ :** គណៈកម្មាធិការជាតិនេះ មានទីស្នាក់ការនៅទីស្តីការរដ្ឋមន្ត្រី ក្រសួងសាធារណការ និងដឹកជញ្ជូន និងមានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងសាធារណការ និងដឹកជញ្ជូន ។

**មាត្រា ៤ :** សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន ក្រសួងការពារជាតិ ក្រសួងមហាផ្ទៃ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្រសួងអភិវឌ្ឍន៍ជនបទ ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលប្រចាំរាជធានីភ្នំពេញ អភិបាលខេត្តកណ្តាល អភិបាលខេត្តកំពង់ស្ពឺ និងក្រសួងស្ថាប័នពាក់ព័ន្ធត្រូវទទួលបន្ទុកអនុវត្តតាមខ្លឹមសារ នៃអនុក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

| | |
|---|---|
| នាយករដ្ឋមន្ត្រីទី ១ | នាយករដ្ឋមន្ត្រីទី ២ |
| ព្រះហស្តលេខា និង ត្រា | ហត្ថលេខា និង ត្រា |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |

* * *

រាជធានីភ្នំពេញ,ថ្ងៃទី ២៤ ខែ សីហា ឆ្នាំ ១៩៩៥

**អនុក្រឹត្យ លេខ ៩៤ អនក្រ.តត**

**ស្តីពីការតែងតាំងមន្ត្រីរាជការ**

**រាជរដ្ឋាភិបាលកម្ពុជា**

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា